# ធម៌ ទាំងឡាយ កើតមកអំពីហេតុ ។

ដូច្នេះ

បើហេតុ រលត់ ធម៌នោះក៏រលត់

បើហេតុ ដូរ ធម៌នោះក៏ដូរ ។

| ៦ |
|---|

## ធម៌ទាំងឡាយ កើតមកអំពីហេតុ

*ខ្ញុំសូមលើកធម៌ព្រះពុទ្ធដូចខាងក្រោមនេះមកអធិប្បាយ៖*

**យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ អាហ**

**តេសញ្ច យោ និរោធោ ច ឯវំ វាទី មហាសមណោ ។**

*ប្រែថា ៖* ធម៌ទាំងឡាយឯណាដែលចេញពីហេតុ, ព្រះតថាគតតែងពោលនូវហេតុនៃធម៌នោះ ម្យ៉ាងទៀតសេចក្តីរលត់និងឧបាយឯណាជាគ្រឿងរលត់នៃធម៌នោះ តថាគតបានពោលហើយនូវសេចក្តីរលត់នោះ, ព្រះមហាសមណៈមានប្រក្រតីពោលពាក្យ យ៉ាងនេះឯង ។

*ធម៌នេះមានប្រយោជន៍ណាស់ចំពោះការរស់នៅនៃយើងសព្វថ្ងៃនេះ ដូច្នេះគប្បីយកធម៌នេះមកពិចារណាឲ្យបានយល់ច្បាស់ ដើម្បីសេចក្តីសុខចំរុងចម្រើននៃយើងគ្រប់ៗគ្នា ។ ជាដំបូង យើងពិចារណា នូវន័យរបស់ពាក្យដែលប្រើក្នុងធម៌នេះ ដូចជា ពាក្យថា* «ធម៌ទាំងឡាយ» *ម្តេចមិនប្រើពាក្យ « ធម៌ទាំងអស់ » ។ នេះមកពីមានធម៌ខ្លះដែលមិនចេញមកពីហេតុ ដូចជានិព្វានជាដើម ។ ពីព្រោះនិព្វាន មិនកើត* (non-né) *ជា អមតៈ បើកើត ត្រូវតែស្លាប់ ។ ក្រៅពីនិព្វាន ធម៌ទាំងអស់សុទ្ធតែចេញពីហេតុ ពីព្រោះជាធម៌*

កើតមកពីគ្រឿងផ្សំ គឺថាបានមកដោយការផ្សំធម៌ដទៃឯទៀត ។ ក្នុងឃ្លាទីពីរ ឃ្លាទីបី « ព្រះតថាគតតែងពោលនូវហេតុនៃធម៌នោះ ម្យ៉ាងទៀតសេចក្ដីរលត់និងឧបាយឯណាជាគ្រឿងរលត់នៃធម៌នោះ តថាគតបានពោលហើយនូវសេចក្ដីរលត់នោះ» ចំពោះធម៌ដែលកើតដោយហេតុ ព្រះពុទ្ធតែងសម្ដែងពីហេតុនៃធម៌នោះ និង វិធីដើម្បីនឹងរំលត់ហេតុនោះ ក៏ព្រះអង្គបានពោលរួចហើយដែរ ដូចមាននៅក្នុងធម៌ អរិយសច្ចៈ ឬ បដិច្ចសមុប្បាទ ជាដើម ។

តាមធម្មតា ធម៌មិនមែនកើតឡើងឯងៗដោយចៃដន្យ ឬ ដោយគ្មានហេតុនោះទេ នេះតាមធម៌ព្រះពុទ្ធ ។ ធម៌ព្រះពុទ្ធនេះយើងប្រើរាល់ថ្ងៃ មិនថាចាស់ ឬ ក្មេងទេ ។ ដូចកូនក្មេងពីរនាក់ទាស់គ្នា អាធំវាយ អាតូចៗ ដល់អាតូចយំ វាសួរទៅអាធំថា « **ហេតុ** អ្វីបានមកវាយអញ » អាធំឆ្លើយថា « **មកពី** ឯងវាយប្អូនអញ » ។ ក្នុងឧទាហរណ៍នេះ ផលគឺ « អាធំវាយអាតូច » ហេតុគឺ « អាតូចបានវាយប្អូនអាធំ » ហើយន័យតាមធម៌ព្រះពុទ្ធ គឺ ៖ **មិនដែលនៅសុខៗ ស្រាប់តែមានគេមកវាយនោះទេ វាសុទ្ធតែមានហេតុ** ។ ក្នុងជីវិតរស់នៅសព្វថ្ងៃ បើយើងប្រើធម៌នេះជានិច្ច សម្រាប់ដោះស្រាយនូវបញ្ហាផ្សេងៗ នោះយើងនឹងចំណេញពេលវេលាផង ហើយថែមទាំងអាចដោះស្រាយបញ្ហាបានដោយឆាប់រហ័សផង ។ ពីព្រោះកាលណាយើងរកហេតុឃើញ នោះយើងអាចដោះស្រាយបញ្ហាបាន ដោយគ្រាន់តែយកហេតុនោះមកដោះស្រាយ ។

កាលខ្ញុំនៅប្រកបការងារនៅឡើយ ដោយខ្ញុំធ្វើការខាងព័ត៌មានវិជ្ជា (informatique) កាលណាប្រូក្រាម([1]) (programme) មិនដើរ ឬ ក៏ដើរមិនត្រូវនោះដើម្បីរក ហេតុ ដែល

[1] នៅ ព័ត៌មានវិជ្ជា (Informatique) ឬ បច្ចេកវិទ្យា (IT), ប្រូក្រាម (programme) គឺជា អត្ថបទ ដែល

ធ្វើឲ្យប្រូក្រាមដើរខុស អ្នកប្រូក្រាម៉ើ គេសរសេរថែមក្នុងប្រូក្រាម ត្រង់បន្ទាត់ខ្លះ ដាក់ជាពាក្យចំណាំ ដូចជាថា « ចំណុចទី១ » ដល់ឆ្ងាយបន្តិចក្នុងប្រូក្រាមដដែល គេសរសេរ « ចំណុចទី ២ » ...។ល។ ហើយត្រង់ចំណុច នីមួយៗ គេឲ្យ ប្រូក្រាមបញ្ចេញលទ្ធផលដែល ម៉ាស៊ីនឲ្យ ។

ដោយធ្វើរបៀបនេះ ប្រូក្រាម៉ើអាចដឹងថាតើចាប់ពីចំណុចណាទៅ មាស៊ីនឲ្យលទ្ធផលខុស ។ ឧបមា នៅ « ចំណុចទី៣ » មាស៊ីនឲ្យលទ្ធផលត្រូវ ហើយដល់ « ចំណុចទី៤ » មាស៊ីនឲ្យលទ្ធផលខុស នោះគេអាចសន្និដ្ឋានថា ហេតុដែលនាំឲ្យ មាស៊ីនឲ្យលទ្ធផលខុស នោះគឺផ្នែក ប្រូក្រាមដែលនៅក្នុង ចន្លោះ « ចំណុចទី៣ » និង « ចំណុចទី៤ » ។

ប្រយោជន៍មួយទៀត របស់ធម៌នេះ គឺ ធ្វើកុំឲ្យយើងអស់សង្ឃឹម ក្នុងការរកហេតុ ពីព្រោះចំពោះព្រឹត្តិការណ៍ខ្លះ ហេតុអាចមានច្រើន ហើយដើម្បីរកហេតុ ដែលជាហេតុពិតនៃព្រឹត្តិការណ៍នោះ ត្រូវប្រើពេលច្រើន តែបើយើងជឿជាក់ថាហេតុត្រូវតែមានជានិច្ច នោះយើងនឹងខំរកហេតុពិតនោះទាល់តែឃើញ ។

ឧបមា ដូចយើងមានទោចក្រយាន (រទេះកង់) ថ្ងៃមួយស្រាប់តែកៅស៊ូកង់វាធូរស្ប៉ត ។ ព្រឹត្តិការណ៍ គឺ កៅស៊ូកង់វាធូរស្ប៉ត តើហេតុមកពីអ្វី ? ដោយយើងពុំបានឃើញនៅពេលដែលកៅស៊ូនោះវាធូរ ដូច្នេះដើម្បីដោះស្រាយយើងត្រូវ សាកល្បងនូវហេតុដូចជា (មុតបន្លា ឬ ដែកគោល) (ខ្យល់ចេញតាមក្បាលវ៉ាល់) (មានគេលួចបន្ធូរ ) ជាដើម ។ ការពិបាកមួយទៀតគឺរកហេតុដើម ឬ មូលហេតុ ។ បើយើងឃើញតែហេតុជិតៗទេ ចំ

---

មនុស្ស សរសេរ ដោយប្រើភាសាពិសេស ដែលម៉ាស៊ីនកុមព្យូទ័រ (computeur) អាចយល់បាន ។ នេះជារបៀបមួយ ដែល មនុស្ស និង ម៉ាស៊ីន អាចនិយាយគ្នាទៅវិញទៅមក ។ មនុស្សដែលសរសេរ អត្ថបទនោះ គេហៅថា ប្រូក្រាម៉ើ (programmeur) ។

ណោទនោះដោះស្រាយបានតែមួយពេលប៉ុណ្ណោះ តែកាលណាមូលហេតុវាផ្តល់ផលមកម្តងទៀត ចំណោទដដែលនោះក៏លេចឡើងជាថ្មី ។ ដូចជម្ងឺដែលមើលមិនជា ជាដើម។ ចំពោះថ្នាំខ្លះ មេរោគវាគ្រាន់តែខ្សោយកម្លាំង តែវាមិនងាប់ ដូច្នេះដល់វាមានកម្លាំង វាក៏ងើបឡើងម្តងទៀត។ បើនិយាយពីកិលេស តណ្ហា ក៏ដូចគ្នាដែរ បើយើងធ្វើត្រឹមតែ សីល សមាធិ កិលេសគ្រាន់តែទ្រោមៗ ទាល់តែធ្វើ **បញ្ញា** (វិបស្សនា)ទើបឆេះដល់ឫស ។ ដូចដើមឈើ បើយើងគ្រាន់តែអារមែកវាចេញ នោះយើងបានស្រឡះមុខផ្ទះតែពេលកាត់មែកនោះទេ តែក្រោយមកមែកនោះនឹងដុះឡើងជាថ្មីម្តងទៀត ។ ដើម្បីកុំឲ្យវាដុះបាន ទាល់តែកាត់គល់កាត់ឫសវាឲ្យដាច់ត្និលតែម្តង ។

ឧទាហរណ៍មួយទៀតដែលបង្ហាញថាការរកមូលហេតុជាការពិបាក ដូចជា ហេតុដែលនាំឲ្យ ប្រជាជនគ្មានការធ្វើ (problème de chômage) អំពើពុករលួយ នៅប្រទេសក្រីក្រ (la corruption dans des pays pauvres) ជាដើម ។

ដោយ « ធម៌ទាំងឡាយ កើតមកអំពី ហេតុ » យើងអាចទាញយកអនុសាធ្យ (corollaire) ដូចជា ៖

១- បើហេតុមិនផ្លាស់ប្តូរ ផលក៏មិនផ្លាស់ប្តូរ ដូចជា បើមិនជួសជុលកៅស៊ូកង់ដែលធ្លូរស៊្បែតនោះទេ កុំសង្ឃឹមថាកៅស៊ូកង់ត្រឡប់មកតឹងវិញឡើយ ។

២- ដើម្បី ផលដូរ លុះត្រាតែហេតុដូរ ដូចជា អ្នកធាត់ចង់ស្គម ទាល់តែដូរហេតុដែលនាំឲ្យធាត់ ដូចជាបន្ថយចំណីអាហារជាដើម ។

៣- បើចង់ឲ្យផលរលត់ ទាល់តែហេតុរលត់ ដូចជា ទុក្ខ កើតមកអំពី **លោភ** ដូច្នេះដើម្បីទុក្ខរលត់ ទាល់តែលោភរលត់ ។ បើនិយាយពីការរត់គ្រឿងញៀនវិញ ការរត់គ្រឿងញៀនរលត់ កាលណាការដាំគ្រឿងញៀនរលត់ ពីព្រោះថាបើអត់មានអ្នកដាំ ក៏អត់មានអ្នកលក់ដែរ ពីព្រោះអត់មានរបស់លក់ ។ មុននឹងបញ្ចប់ខ្ញុំសូមធ្វើការសង្កេតខ្លះ

ក្នុងការអនុវត្ត « ធម៌ទាំងឡាយកើតមកអំពីហេតុ »។ ដោយក្នុងការនិយាយយើងច្រើនតែប្រើពេលបច្ចុប្បន្នជានិច្ច ថ្វីបើ អំពើបានធ្វើរួចទៅហើយ ឬ ក៏នឹងធ្វើនៅពេលខាងមុខ ។ ដូចនៅក្នុងឃ្លា « ធម៌ទាំងឡាយកើតមកអំពីហេតុ » បានន័យថា ធម៌ នោះកើតក្រោយហេតុ ។ ពោល គឺ ធម៌កើតក្រោយ តែ ហេតុកើតមុន ។ ហើយធម៌ នីមួយៗ ដែល កើតលេចចេញមក អាចមានហេតុដើមដំបូង ដែលខុសពីហេតុចុងក្រោយ ។ មកដល់ត្រង់នេះ លោកអ្នក អាចនឹកថា « វាច្បាស់តែយ៉ាងនេះហើយ មិនចាំបាច់និយាយ ក៏ដឹងដែរ »។ លោកអ្នកនឹងឃើញផលប្រយោជន៍ នៃការសង្កេតនេះ ។ ដោយខ្ញុំធ្លាប់ឮក្នុងធម៌អភិធម្មមានពាក្យថា «ហេតុជិត» គឺហេតុអមហេតុចុងក្រោយនៃធម៌ ខ្ញុំក៏នឹកថា បើមានហេតុជិត ក៏ត្រូវមានហេតុឆ្ងាយដែរ គឺហេតុដំបូងគេ ហើយ ហេតុដើមដំបូងនេះឲ្យផល តៗមក រហូតដល់ចុងបញ្ចប់ ធម៌ ក៏កើតឡើង ។ ឧបមាដូចជាយើងកំពុងតែដើរៗ ស្រាប់តែភ្លៀងធ្លាក់ខ្លោកៗ ធ្វើឲ្យទទឹកខោអាវអស់ ។ យើងច្រើននិយាយថា ទទឹកខោអាវមកពីភ្លៀង ។ និយាយនេះត្រូវ មួយរយភាគរយ (100 %) ពីព្រោះហេតុដែលនាំឲ្យទទឹកខោអាវ គឺ មេឃភ្លៀង ។ តែចំពោះយើងដែលមិនចង់ ឲ្យទទឹកភ្លៀងទៅថ្ងៃមុខ តើគ្រាន់តែ**យល់ថា** មកពីភ្លៀងបានជាខោអាវទទឹក **តើគ្រប់គ្រាន់សម្រាប់ថ្ងៃមុខទេ**? បើលោកអ្នកយល់ដូចខ្ញុំដែរ គឺថា « មិនទាន់គ្រប់គ្រាន់ ទេ» នោះយើងត្រូវស្រាវជ្រាវ រកឫសគល់ហេតុការណ៍នេះ តទៅទៀតៗ ដូចនៅក្នុងឧទាហរណ៍ទទឹកភ្លៀងនេះ យើងសួរថា ហេតុអ្វីបានជាភ្លៀង? បើយើងថាមកពី ខ្យល់ក្តៅ ប៉ះនឹងខ្យល់ត្រជាក់ក្នុងពពក នោះថ្វីបើយើងពុំអាចកែរច្បាប់ធម្មជាតិកុំឲ្យមេឃភ្លៀងបានក៏ដោយ តែយើងអាចរកមធ្យោបាយកុំឲ្យទទឹកជោកតទៅទៀតបានដែរ ។ មធ្យោបាយគឺ ពេលណាមេឃមានពពកខ្មៅហើយ យើងទៅណាមកណាត្រូវមានឆ័ត្រ ឬ អាវភ្លៀង បើយើងខ្លាចទទឹកភ្លៀង។

ខ្ញុំសូមជូនឧទាហរណ៍មួយទៀត ដែលជាប់ទាក់ទងនឹងការប្រតិបត្តិ ធម៌ព្រះពុទ្ធ ។ ក្នុងការបង្រៀនធម៌ព្រះពុទ្ធ មានលោកគ្រូខ្លះពន្យល់ថា ចំពោះធម៌នាំឲ្យបានសម្រេចព្រះនិព្វាន ឲ្យតែយល់ច្បាស់ត្រឹមត្រូវ នូវធម៌នោះទៅ នឹងបានសម្រេចហើយ មិនចាំបាច់មានការបដិបត្តិទេ ពីព្រោះការបដិបត្តិនៅក្នុងការយល់នោះហើយ ។ ត្រង់ឃ្លានេះ ខ្ញុំពុំយល់ស្របទេ ពីព្រោះនៅក្នុងគម្ពីរ មានដំណាលថា មានព្រះសង្ឃមួយអង្គជាគ្រូ បានបង្រៀនសិស្សជាច្រើន ។ ដល់ក្រោយមក សិស្សបានសម្រេចជាព្រះអរហន្ត តែចំពោះលោកគ្រូនោះវិញ អត់បានសម្រេចអ្វីទាំងអស់ ។ បើថាមកពីព្រះសង្ឃគ្រូអង្គនោះ មិនយល់ធម៌ព្រះពុទ្ធក៏មិនសម ពីព្រោះមុននឹងពន្យល់ធម៌ដល់សិស្សទាល់តែលោកគ្រូយល់ធម៌នោះជាមុនដែរ ។

ដល់ក្រោយមក ដោយប្រតិបត្តិតាមការណែនាំរបស់សាមណេរអរហន្តមួយអង្គ ដែលធ្លាប់ជាកូនសិស្សលោកគ្រូនោះដែរ ទើបបានសម្រេចជាព្រះអរហន្ត ។ នេះបង្ហាញឲ្យឃើញថា បើត្រឹមតែយល់ធម៌ព្រះពុទ្ធអាចមិនទាន់គ្រប់គ្រាន់ទេ ចំពោះមនុស្សទូទៅ ត្រូវបដិបត្តិនិងអប់រំចិត្តថែមទៀតទើបបានសម្រេចមគ្គផល ។

ម្យ៉ាងទៀត ជនគ្រប់រូបមានឧបនិស្ស័យមិនដូចព្រះសារីបុត្តទេ ដែលគ្រាន់តែស្តាប់ធម៌ព្រះ អស្សជិ តែប៉ុន្មានម៉ាត់ ក៏បានសម្រេចជាសោតាបន្នបុគ្គល ។ នៅក្នុងអរិយសច្ច៤ កាលណាយើងកំណត់ដឹងនូវទុក្ខ យើងនឹងយល់ថា កិលេស តណ្ហា ជាហេតុនាំឲ្យកើតទុក្ខ ។ ដោយផ្លូវទៅនិព្វាន គឺ **លះ**កិលេស តើគ្រាន់តែយល់ អរិយសច្ច៤ ប៉ុណ្ណឹង អាចលះកិលេសអស់ទេ ?

ប្រសិនបើជាលះមិនអស់ តើធ្វើដូចម្តេច ?

ចម្លើយ គឺត្រូវរកហេតុដើមដំបូង នៃលោក ដូចគ្នានឹងរកហេតុដែលធ្វើឲ្យមេឃភ្លៀង ។ តើរកហេតុដើមនោះដោយរបៀបណា ? អត់ពិបាកទេ ព្រះពុទ្ធទ្រង់បានទុកធម៌ព្រះ

អង្គ ឲ្យដល់យើងគ្រប់គ្រាន់ហើយ មិនចាំបាច់ទៅបង្កើតថ្មី ឬ ទៅរកឯណាឆ្ងាយទេ ។
ខ្ញុំសូមដកស្រង់ ធម៌បដិច្ចសមុប្បាទ មកជូនដូចតទៅ ៖
នាមរូប ជាបច្ច័យឲ្យកើត សឡាយតនៈ ។ ដើម្បីខ្លីខ្ញុំសរសេរជា នាមរូប => សឡាយតនៈ ។
[នាមរូប => សឡាយតនៈ => ផស្សៈ =>វេទនា ] => [ **តណ្ហា** => ឧបាទាន ] គឺ កិលេស។
[ សីល - សមាធិ - សតិបដ្ឋាន ៤ - វិបស្សនា ] **=>** អស់ [តណ្ហា ] => អស់ [ឧបាទាន ] ។
ខ្ញុំសូមពន្យល់ និង អធិប្បាយ ប្រយោគ ទាំងពីរនេះ ដូចតទៅ ៖
កិលេស គឺគ្រឿងសៅហ្មងចិត្ត ដូចជា លោភៈ ទោសៈ មោហៈ ជាដើម ។
នាមរូប តាមភាសាអ្នកស្រុក គឺ មនុស្សយើងគ្រប់រូប ។ បើតាមភាសាធម៌ គឺ ខន្ធ ៥ មាន រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ ដើម្បីលះ តណ្ហា យើងប្រើ រូប ដូចជា ភ្នែក ត្រចៀក ច្រមុះ ជាដើម ។ ហើយយើងប្រើនាម គឺចិត្ត ដូចជា វេទនា សតិ ជាដើម ឲ្យទៅឃាំង កិលេស កុំឲ្យវាកើតបាន ។ ពោលគឺ យើង យកចិត្តអលោក ទៅ ឃាំង រាំង ចិត្តលោក ។ ពីព្រោះចិត្ត មានចិត្តកុសលក៏មាន ចិត្តអកុសល ក៏មាន ។ បើយើងចេះ ប្រើចិត្ត យើងយកចិត្តកុសល ទៅ កំចាត់ចិត្ត អកុសល ។
ដើម្បីប្រើចិត្តបាន ទាល់តែយើងចេះអប់រំវា ថ្វីបើវាមិនមែនជារបស់យើងក៏ដោយ ។ ដូច យើងឃើញស្រាប់ហើយ ដំរី មិនមែនជារបស់យើងទេ[2] ហើយវាខ្លាំងជាងយើងទៀតផង តែដោយការអប់រំរបស់ ហ្មូ ដំរីក៏ស្លូតទៅជាមានប្រយោជន៍ដល់ម្ចាស់វាទៅវិញ ។
វិធីអប់រំចិត្ត ព្រះអង្គមានចែងទុករួចមកហើយ នៅតែយើងចេះយកមកប្រើទេ ។

---

[2] ពីព្រោះតាមធម៌ គ្មានអ្វីជារបស់យើងទេ សូម្បីតែខ្លួនយើងសព្វថ្ងៃនេះ ក៏មិនមែនជារបស់យើងដែរ សូមអាន កថាខ័ណ្ឌ បន្ត ស្តីពី អត្តា ជាបន្ទាប់នេះ ។

សឡាយតនៈ គឺ ទ្វារទាំង ៦ខាងក្នុងខ្លួនយើង មាន ៖ ទ្វារភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយ ទ្វារចិត្ត ។ ហើយរបស់នៅ ខាងក្រៅ ខ្លួនយើង ដូចជា រូប សំឡេង ក្លិន រសជាតិ ផោដ្ឋព្វ (របស់ដែលកាយប៉ះ) និង ធម្មារម្មណ៍ ។ របស់ ខាងក្រៅ ទាំង ៦នេះ អាចចូលមកក្នុងខ្លួនយើងបាន តាមទ្វារភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយ ទ្វារចិត្ត ។ យើងដឹងវាចូលមកនៅក្នុងខ្លួនយើងដោយ វេទនា ដូចជា មានការ សុខស្រួល (ហៅថាសុខវេទនា) ឬ មានការឈឺចុកចាប់ (ហៅថាទុក្ខ វេទនា) ជាដើម ។ ឧបមា មាន រូបល្អចូលតាមទ្វារភ្នែក បើយើងពេញចិត្ត ក៏ស្រឡាញ់ចង់ បាន កើតជាតណ្ហា។ ដល់ជាប់ជំពាក់ខ្លាំងចិត្តក៏ក្លាយទៅជាឧបាទាន (ការប្រកាន់មាំ) ។ ក៏ដូចគ្នា ចំពោះសំឡេង ឬ ក្លិន ។ បើសំឡេងពិរោះក៏ស្រឡាញ់ បើមិនពិរោះក៏ស្អប់ ។ ក្នុងឧទាហរណ៍នេះ យើងឃើញថា តណ្ហា អាចចូលតាមទ្វារទាំង ៦ ដូចជាទ្វារភ្នែក ជាដើម ។ ដូច្នេះ ដើម្បី កុំឲ្យ តណ្ហាចូលតាមទ្វារភ្នែកបាន តើត្រូវធ្វើដូចម្តេច ? នេះហើយជាសំណួរនៃការប្រតិបត្តិ មិនមែនគ្រាន់តែ **យល់** ថាតណ្ហា ចូលតាមភ្នែក ហើយក៏ អស់តណ្ហានោះទេ ។ របៀបប្រតិបត្តិមានគ្រប់គ្រាន់ តាំងពីសម័យព្រះពុទ្ធមក មិនពិបាករកទេ ។ គឺ សមាធិ សតិបដ្ឋាន ៤ វិបស្សនា [3]។ ការបដិបត្តិ គឺ ដើម្បីឲ្យ មាន **សតិដឹងទាន់** កាលណាចិត្តមានរាគៈ ។

បើនិយាយតាមភាសាអ្នកស្រុក បើកាលណាចោរវាចូលតាមទ្វារភ្នែក យើងដឹងថាចោរ ចូលតាមទ្វារភ្នែកហើយ គឺ គ្រាន់តែដឹងបានហើយ មិនចាំបាច់ទៅដេញវាទេ ។ ដូចចោរ ចូលលួច កាលណាវាដឹងថាយើងឃើញវាហើយ វារត់ទៅឯង។ បើមិនមានចោរ ទេ ក៏ដឹងថា មិនមានចោរ ។ សំខាន់គឺ យើងមិនធ្វេសប្រហែស ដោយមានសតិ គឺការ

[3] ខ្ញុំ គ្រាន់តែជំរាបថាមាន ប៉ុណ្ណោះទេ បើលោកអ្នកចង់ស្គាល់ របៀបប្រតិបត្តិទាំងនោះ សូមអញ្ជើញ អានសៀវភៅស្តីពី សមាធិ ឬ បញ្ញា (វិបស្សនា) តាមបំណង។

ប្រុងប្រយ័ត្ន គ្រប់ពេលវេលា ។ បើនិយាយជាភាសាធម៌វិញ ដែលថា មិនមានយើង មិនមានចោរ នោះយើងអាចថា ចោរជាតណ្ហា (ចិត្តអកុសល) ហើយយើងជាអ្នកយាមខ្លាចចោរចូលផ្ទះ គឺ សតិ (ចិត្តកុសល) ដែលតាំងនៅចាំត្រង់ទ្វារភ្នែក ។ កាលណា ភ្នែកឃើញរូបល្អ សុខវេទនាក៏កើតឡើង នៅពេលនោះ បើសតិដឹងទាន់ ពោលគឺសតិមិនបានដេកលក់ នោះសេចក្ដីស្រឡាញ់រូបល្អក៏ចូលតាមទ្វារភ្នែកមិនបាន ពីព្រោះមានសតិនៅទីនោះរួចទៅហើយ ។ នេះជាច្បាប់ធម្មជាតិរបស់ចិត្ត ដូចជាមនុស្សល្អ និង មនុស្សអាក្រក់ រស់នៅជាមួយគ្នាមិនកើតទេ[4] យ៉ាងណាមិញ ចិត្តកុសល និង ចិត្តអកុសល ក៏នៅជាមួយគ្នាមិនបានដែរ គឺថា ៖ បើមួយមាន មួយគ្មាន ។

នៅក្នុង **ចិត្តានុបស្សនាសតិបដ្ឋាន** មានចែងថា ៖

***នែភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយ រាគៈ ដឹងច្បាស់ថា « ចិត្តប្រកបដោយ រាគៈ » ទោះចិត្តប្រាសចាករាគៈ ដឹងច្បាស់ថា « ចិត្តប្រាសចាករាគៈ »*** ។

នេះគ្រាន់តែចង់បង្ហាញថា បើលោកអ្នកត្រូវការបដិបត្តិ របៀបបដិបត្តិមាន។

---

[4] កាលសម័យព្រះ មានរឿងមួយតំណាលថា មានកូនស្រីសេដ្ឋីម្នាក់ ទៅស្រឡាញ់ចោរ ហើយសុំឪពុកម្ដាយ យកចោរនោះមកធ្វើជាប្ដី ។ លុះបានគ្នាជាប្ដីប្រពន្ធហើយ ដល់គ្រាក្រោយមក ប្ដីនោះមិនចេះរស់នៅជាមួយនឹងភរិយាខ្លួន ក៏បបួលនាងទៅលាបំណន់គ្រូនៅលើកំពូលភ្នំ លុះដើរទៅដល់ជ្រោះភ្នំ ក៏បង្គាប់ទៅនាងកូនសេដ្ឋី ឲ្យដោះគ្រឿងអលង្ការមកឲ្យខ្លួនមុននឹងគេប្រានាងឲ្យធ្លាក់ស្លាប់ក្នុងជ្រោះភ្នំនៅពេលនេះ។ នាងនោះក៏សុខចិត្តធ្វើតាមបង្គាប់ចោរ លុះបានដោះគ្រឿងអលង្ការអស់ហើយ នាងក៏និយាយទៅប្ដីថា មុននឹងយើងបែកគ្នា ខ្ញុំសូមរាំជូនលោកប្ដីសិន។ ចោរក៏សុខចិត្តឲ្យនាងនោះរាំ ដល់ចោរមើលកាន់តែជក់ចិត្ត ភ្លេចខ្លួន នាងកូនសេដ្ឋីក៏រុញច្រានចោរនោះធ្លាក់ក្នុងជ្រោះស្លាប់ទៅ ។ រឿងក្បោះក្បាយជាងនេះ តែខ្ញុំយកតែកន្ទ្រងដែលបញ្ជាក់ថា មនុស្សល្អ និង មនុស្សអាក្រក់ មិនចេះរស់នៅជាមួយគ្នាទេ ។

មុននឹងបញ្ចប់ ខ្ញុំសូម ធ្វើការអធិប្បាយ អំពីពាក្យ យល់ ជឿ និង ជឿដោយប្រើបញ្ញា ពីព្រោះពាក្យទាំងបីនេះ ទាក់ទងនឹងពាក្យ ហេតុ ។

<u>យល់ ដូចជា យល់ធម៌ ជាដើម</u>

បានន័យថា យើងយល់នូវហេតុដែលបណ្ដាលឲ្យធម៌នោះកើត ។ សុរា ធ្វើឲ្យមនុស្សស្រវឹង វង្វេងស្មារតី ។ យើងយល់ដោយធ្លាប់បានឃើញ មនុស្សស្រវឹងស្រា និយាយផ្ដេសផ្ដាស ដើររកជល់គេជល់ឯង ។ តែចំពោះអ្នកវិទ្យាសាស្ត្រគេយល់ដោយ ឃើញជាតិសុរាចូលតាមឈាមទៅដល់ខួរក្បាល រួចហើយក៏ធ្វើឲ្យមនុស្សវង្វេងសប្រហែស ។

<u>ជឿ ដូចជា ជឿធម៌ ជាដើម</u>

ជឿធម៌ គឺជឿថាធម៌នោះត្រូវ ដោយមិនរវល់រកហេតុផល ពីព្រោះទុកចិត្ត លើអ្នកដែលយកធម៌នោះមកផ្សាយ ដូចជា ព្រះសង្ឃ ឬ លោកធម្មាចារ្យជាដើម។

<u>ជឿដោយប្រើបញ្ញា</u> គឺមុននឹងជឿ គេពិចារណារកហេតុផលសិន ពីព្រោះធម៌ទាំងឡាយកើតមកអំពីហេតុ ។ ហើយចំពោះ ធម៌ខ្លះដែលពិបាកនឹងយល់ គេយកធម៌នោះទៅធ្វើការពិសោធន៍ដោយខ្លួនឯងជាមុនសិន មុននឹងថា ជឿ ឬមិនជឿ គឺ មុននឹងថា ធម៌នោះត្រូវ (ឲ្យបុណ្យ ឲ្យសុខ) ឬ មិនត្រូវ (ឲ្យបាប ឲ្យទុក្ខ) ។

នេះក៏ជាពាក្យប្រៀនប្រដៅមួយដែរ របស់ព្រះយើង ។ ពីព្រោះការពិសោធន៍ ជា **ការប្រតិបត្តិ** ដែលអាចជួយយើងឲ្យឆាប់យល់ ។ ដូចជានៅសាលា ក្នុងការសិក្សាគណិតសាស្ត្រ (Mathématiques) ឬ រូបសាស្ត្រ-គីមី (Physique-Chimie) ក៏មានធ្វើលំហាត់ធ្វើការពិសោធន៍ ដែរ ។

យកពាក្យថា « ធម្មទាំងឡាយ កើតមក អំពីហេតុ » មកអនុវត្ត ក្នុងជីវិតរស់នៅសព្វថ្ងៃនេះ នាំឲ្យយើងបានសេចក្ដីសុខច្រើន អាចបន្ថយការខឹងនឹងអ្នកដទៃ បានខ្លះ ដូចជា ខឹងនឹងអ្នកដឹកនាំប្រទេសជាតិជាដើម ។

ឧទាហរណ៍ ខ្ញុំធ្លាប់ខឹងនឹងអ្នកដែលមិនគោរពម៉ោងពេលដែលបានណាត់គ្នារួចហើយដែរ ។ មានពេលខ្លះខ្ញុំចាំគេរាប់ម៉ោង ទម្រាំគេមកដល់ ហើយដល់ពេលគេប្រាប់ខ្ញុំនូវហេតុពិតដែលធ្វើឲ្យគេមកយឺតនោះ ខ្ញុំក៏ឈប់ខឹងនឹងគេទៅ ។ ដូចជាយើងក៏ធ្លាប់ខឹងនឹងអ្នកដឹកនាំប្រទេសជាតិ ថាម្ដេចក៏មិនធ្វើបែបនេះទៅ ដើម្បីនឹងបន្ថយចំនួន អ្នកអត់ការងារធ្វើ ។ ការពិតការដឹកនាំប្រទេស ក៏មិនស្រួលជាខុសនឹងការដឹកនាំគ្រួសារដែរ ។ ក្នុងគ្រួសារនីមួយៗ អ្នកណាមិនចង់មានបានដូចគេឯង ហើយម្ដេចក៏នៅតែមានគ្រួសារអ្នកក្រដែរ ។ តើហេតុពិត មកពីអ្វី ? ដូច្នេះ យើងគប្បី ដឹករក ហេតុពិតជាមុនសិន មុននឹងខឹង មុននឹងបន្ទោស អ្នកដទៃ ។